# មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI0171**

## សម្ភាសន៍ជាមួយឈ្មោះ ឃ ម៉ុត ភេទស្រី អាយុ៥២ឆ្នាំ
## មុខងារជំនាន់ខ្មែរក្រហម "ប្រជាជនធ្វើការនៅកងចល័ត និងប្រធានកង "
## រស់នៅភូមិប៉ោយព្រីង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ
## ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១
## សម្ភាសន៍ដោយៈ ឆាយ ឈុនលី
## ០១:០៩:៤០
## ៣២ទំព័រ

ឈុនលី ៖ នេះជាសៀវភៅដែលអង្គការខ្ញុំបោះពុម្ព ហើយខ្ញុំសុំណែនាំខ្លួនបន្តិចខ្ញុំឈ្មោះ ឈុនលី មកពីខាងអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយខ្ញុំមកចង់ដឹងពីប្រវត្តិរបស់មីងធ្វើការលំបាកយ៉ាងម៉េចៗកាលនៅសម័យខ្មែរក្រហម ហើយជាពិសេសការងារនៅអាងត្រពាំងថ្ម ហើយមីងបានទៅនោះយូរទេមីង?

ម៉ុត ៖ ធ្វើការនៅនោះម៉ាខែពីរខែទៅលល័តទៅទៀត កន្លះខែជួនកាលទៅបួនដប់ថ្ងៃទៅទៀតចល័តគ្រប់កន្លែង ។

ឈុនលី ៖ ចាស!ហើយពួកខ្ញុំចង់សរសេររឿងរ៉ាវអស់ហ្នឹងទុកឲ្យក្មេងជំនាន់ក្រោយ បានរៀនសូត្រណាសមីងដើម្បីឲ្យដឹងថាត្រពាំងថ្មហ្នឹងពីដើមមកប្រវត្តិវាយ៉ាងម៉េចៗ អ្នកធ្វើការប៉ុន្មាននាក់ចឹងណាស ។ ចឹងក្នុងនោះខ្ញុំសុំថតរូបមីងដែរមីងណាស អត់អីទេហ្អី?

ម៉ុត ៖ អត់អីទេ ។

ឈុនលី ៖ អីចឹងថ្ងៃនេះទី១៧ ខែមិថុនា ឆ្នាំ២០១១ ។ អីចឹងខ្ញុំសុំស្គាល់ឈ្មោះមីងផងមីងឈ្មោះអីគេ?

ម៉ុត ៖ ម៉ុត ។

ឈុនលី ៖ ត្រកូលអីគេ?

ម៉ុត ៖ ត្រកូលអីគេ?

ឈុនលី ៖ ឃ ម៉ុត ។

ម៉ុត ៖ អាយុប៉ុន្មានហើយមីង?

ឈុនលី ៖ ៥២ ។

ម៉ុត ៖ ៥២ ។

ឈុនលី ៖ ៥២ ភេទស្រី នៅភូមិ?

ម៉ុត ៖ ប៉ោយព្រីង ។

ឈុនលី ៖ ឃុំ?

ម៉ុត ៖ ឃុំព្រះនេត្រព្រះ ។

ឈុនលី ៖ មីងមានបងប្អូនប៉ុន្មាននាក់?

ម៉ុត ៖ ៦នាក់ ។

ឈុនលី ៖ ប្រុសប៉ុន្មានស្រីប៉ុន្មាន?

ម៉ុត ៖ ប្រុសបីស្រីបី ។

ឈុនលី ៖ មីងកូនទីប៉ុន្មាន?

ម៉ុត ៖ មានតែបងប្អូនទេហ្អី?

ឈុនលី ៖ ចាស បងប្អូនបស់មីង ។

ម៉ុត ៖ មិនដែលរាប់ផង រាប់សិន ទី៥ ។

ឈុនលី ៖ កូនទីប្រាំ?

ម៉ុត ៖ ចាស!

ឈុនលី ៖ ហើយមីងរៀនបានថ្នាក់ទីប៉ុន្មាន?

ម៉ុត ៖ អត់ ទីអត់ ។

ឈុនលី ៖ អត់ដែលរៀនសូត្រម៉ងហ្អី?

ម៉ុត ៖ អត់ បើកើតមកអាពតតែម៉ងបើរៀនក៏មិនបានរៀន ។

ឈុនលី ៖ ចុះមីងកាលនោះអាយុប៉ុន្មាន?

ម៉ុត ៖ ជំនាន់នោះល្មមរៀនកើតតែឪមិនឲ្យរៀន ព្រោះខ្ញុំនៅចំការធ្វើស្រែ ។

ឈុនលី ៖ ស្រុកកំណើតនៅឯណា?

ម៉ុត ៖ ស្រុកកំណើតនៅនេះឯងតែគាត់ទៅធ្វើចំការនៅគោកយាវរៀនបានតិច ពីសង្គមរៀនបាន តិច បើរៀនសុំគាត់រៀនគាត់មិនឲ្យរៀន ។

ឈុនលី ៖ អីចឹងកាលមុន៧៥ហ្នឹងអាយុប្រហែលដប់ឆ្នាំជាង?

ម៉ុត ៖ ច្រើនហើយមិនដល់ម្ភៃទេ ។

ឈុនលី ៖ ចុះមុនសម័យអាពតមីងធ្វើអីគេ?

ម៉ុត ៖ មានធ្វើអីមានតែធ្វើស្រែចំការ ។

ឈុនលី ៖ ធ្វើនៅឯណាទៅ?

ម៉ុត ៖ នៅគោកយាវនៅខាងជើង នៅខាងណោះថ្នល់បៀតស្រុកខ្វាវ ។

ឈុនលី ៖ ធ្វើស្រែរហូតតាំងពីតូចមក?

ម៉ុត ៖ ធ្វើស្រែរហូតតាំងពីតូចមក ។

ឈុនលី ៖ ម៉េចបានអត់រៀនចឹង?

ម៉ុត ៖ ចុះបើគាត់មិនឲ្យមករៀន កាលនោះយ៉ាកណាស់សុំម៉ែខ្ញុំមករៀនជាមួយមីប្អូន គាត់មិនឲ្យមកសោះ ។

ឈុនលី ៖ ម៉េចបានអីចឹង?

ម៉ុត ៖ វាឆ្ងាយ ។

ឈុនលី ៖ ចុះពេលទៅធ្វើស្រែទៅគោយាវហ្នឹងឃុំហ្អី?

ម៉ុត ៖ ភូមិគោយាវ ។

ឈុនលី ៖ ភូមិគោយាវ ចឹងល្ងាចឡើងមកផ្ទះវិញហ្អី?

ម៉ុត ៖ ទេនៅនោះឯងអត់មានសាលារៀនទេ តែសព្វថ្ងៃនេះអត់មានអ្នកណានៅភូមិនោះទេអស់ហើយ ។

ឈុនលី ៖ ភូមិគោយាវហ្នឹងនៅឃុំអីគេ?

ម៉ុត ៖ នៅឃុំព្រះនេត្រព្រះយើងនេះ ដូចចំការណាស គេហៅចំការគោកគោយាវ ផ្ទះច្រើនដែរតែខែប្រាំងគេមកនៅផ្ទះគេអីណោះវិញដល់ពេលធ្វើស្រែបានគេទៅ ។

ឈុនលី ៖ អីចឹងខែប្រាំងគេមកផ្ទះ?

ម៉ុត ៖ ខែប្រាំងគេមកណោះ ។

ឈុនលី ៖ ហើយចឹងនៅនេះខ្មែរក្រហមចូលឆ្នាំណា?

ម៉ុត ៖ មិនដឹងឆ្នាំប៉ុន្មានទេ ។

ឈុនលី ៖ ៧៥ហ្អី?

ម៉ុត ៖ ខ្ញុំមិនបានចាំទេ វាក្មេង ។

ឈុនលី ៖ ចុះខ្មែរក្រហមចូលមកហ្នឹងមីងនៅឯណា?

ម៉ុត ៖ ខ្ញុំនៅនេះឯង ។

ឈុនលី ៖ មកនៅនេះហើយអត់នៅចំការទេ?

ម៉ុត ៖ អត់នៅទេ ។

ឈុនលី ៖ ម៉េចទៅមីង ចូលមកយ៉ាងម៉េច?

ម៉ុត ៖ ចូលមកយ៉ាងម៉េចវារកដេញម្តងហើយគេរកចាប់រកអី ។

ឈុនលី ៖ មកដល់គេធ្វើម៉េចទៅ?

ម៉ុត ៖ ទៅគេរកចាប់រកអីដេញចាប់ទៅ ។

ឈុនលី ៖ ចាប់ទៅណា?

ម៉ុត ៖ ចាប់ទៅខាងវាទៅរកស៊ីរកចុកអីខាងវា ។

ឈុនលី ៖ មកដល់ប៉ុន្មានថ្ងៃបានគេដេញ?

ម៉ុត ៖ ទេមកដល់យូរហើយបួនប្រាំថ្ងៃទៅ ។

ឈុនលី ៖ ហើយពេលមកដល់ភ្នូមយើងនៅក្នុងផ្ទះយើងមិនខ្លាច?

ម៉ុត ៖ ទេ យើងខ្លាចហើយ ហួស!កាលពួកវាចូលមកខ្ញុំមិននៅនេះទេ ខ្ញុំនៅគោកលន់ ។

ឈុនលី ៖ គោកលន់ហ្នឹងអីគេ?

ម៉ុត ៖ ភូមិគេតាមថ្នល់ណាសជាតិណាស ។

ឈុនលី ៖ ចុះនៅធ្វើអីគោកលន់នោះ?

ម៉ុត ៖ មានធ្វើអីចេះនោះគេចូលមកយើងនៅនេះ ក៏ដេញទៅ ។

ឈុនលី ៖ ភូមិហ្អឹគោកលន់ហ្នឹង?

ម៉ុត ៖ ភូមិគេណាស ភូមិធំតាមផ្លូវជាតិណាស ។

ឈុនលី ៖ ហើយយ៉ាងម៉េចទៀតទៅមីង?

ម៉ុត ៖ មានយ៉ាងម៉េចវាគេមកហៅទៅប្រជុំយកស្រូវ របស់ទ្រព្យខោអាវអី គោក្របីអីប្រមូលយកទៅដាក់រួមគេមិនទុកឲ្យយើងដាក់ឯកជនណាសតាំងពីប្រាក់ញតាំងពីអីគេយកទៅដាក់ការ៉ុងណាសប្រេកបាវអីទុក ដូចប្រាក់អីវារហែករហេតាមផ្លូវជាតិណាសចោលទាំងបាវរហែករហេ ។

ឈុនលី ៖ ចុះមាសគេយក?

ម៉ុត ៖ មាសវាមិនទាន់ប្រមូលទេ គោក្របី...

ឈុនលី ៖ លុយហ្នឹងហ្អី?

ម៉ុត ៖ ហ្នឹងហើយលុយណាស អាលុយសម័យលន់ នល់ហ្នឹងណាសយកបានហើយក៏មិនដឹងទៅចាយនៅឯណាក៏វាក្រវាត់ចោលតាមផ្លូវសក្បុសប្រាក់ហ្នឹងណាស ។ ម៉ែខ្ញុំទុកបាន

ប្រហែលបីបួនប្រាំពាន់ឥឡូវបាត់អស់ហើយនៅសល់ប៉ុន្មានរយបាត់អស់ហើយនៅសល់ប៉ុន្មានរយ ។ កាល សម័យអាពតវាយកទៅចោល ។

ឈុនលី ៖ ហើយយ៉ាងម៉េចទៀតទៅ?

ម៉ុត ៖ មានយ៉ាងម៉េចគេហៅទៅប្រជុំអីណេះអីណោះ បើអ្នកណាធ្វើទាហានធ្វើអីឯណាកូនរដ្ឋមន្ត្រីកូនអីគេយកទៅវៃចោល ។

ឈុនលី ៖ វៃនៅនឹងមុខយើងហ្នឹង?

ម៉ុត ៖ ទេមិនទាន់វៃនៅនឹងមុខយើងទេ គេចាប់ហើយគេចង ។

ឈុនលី ៖ ឃើញដែរ?

ម៉ុត ៖ ចឹមិនឃើញបើចងទាំងខ្សែៗក៏គេហៅឡានមកក៏ឡើងឡានៗទៅអារក្សបាក់កតាមផ្លូវទៅស្វាយ ។

ឈុនលី ៖ អារក្សបាក់ករហ្នឹងអីគេ?

ម៉ុត ៖ កន្លែងគេយកទៅដាក់អ្នកធំអ្នកតូចអីគេយកទៅវៃចោលនៅនោះ ។

ឈុនលី ៖ អាហ្នឹងវាលសំលាប់ហើយចឹង?

ម៉ុត ៖ ចាស គេជីកអន្លង់ធំណាស អន្លង់បួនជ្រុង កូនចៅកូនអីអ្នកគ្រូអីយស្មាទោសបោះទៅលើ ។

ឈុនលី ៖ មីងឃើញ?

ម៉ុត ៖ ចាស បើខ្ញុំលើកទំនប់នៅនោះឯង ក៏ចំពុះទង់ ។

ឈុនលី ៖ ចឹងអាពេលនោះពេលលើកទំនប់ទេមិនមែនពេលខ្មែរក្រហមមកដំបូងទេ?

ម៉ុត ៖ ទេ មកដំបូងណាសតែភូមិខ្ញុំមិនទាន់ឲ្យទៅទេ តែទៅឃើកមើគេជីកទាំងឡានៗទៅ ជីកយកទៅដាក់ទាំងឡានៗជីកអន្លង់បួនជ្រុងអីចេះក៏ដាក់ម៉ាជំបងពោកគ្គុកទៅ អន្លង់គេជីកបួនជ្រុងតែជ្រៅណាស ។

ឈុនលី ៖ អាហ្នឹងពេលណាហើយ?

ម៉ុត ៖ ពេលកាលដែលខ្មែរក្រហមចូលមកដំបូងនោះ ។

ឈុនលី ៖ ហេតុអីបានវៃអ្នកហ្នឹងយ៉ាងម៉េចបានវៃ?

ម៉ុត ៖ គេថាយើងជាប់ប្រវត្តិទាហានណាស ។

ឈុនលី ៖ គេយកបញ្ជីមកដែរ?

មុំត ៖ ទេដូចគេមានអីបើដូចគេសេនាជន យោធាអីគេកត់ទៅ ហើយប្រធានភូមិយើងគេកត់ថា អ្នកនេះទាហានអ្នកនោះទាហានអានេះជាប់ប្រវត្តិទាហានលោកធំអីគេចាប់ទាំងអស់ ។

ឈុនលី ៖ ប្រជុំនៅឯណា?

មុំត ៖ ប្រជុំនៅផ្ទះប្រធានភូមិ ។

ឈុនលី ៖ ចឹងទៅចន្លុលប្រាប់តែម្តងហ្អី?

មុំត ៖ ហ្នឹងហើយអ្នកនេះទាហានអ្នកនោះទាហានទៅគេចាប់ ។

ឈុនលី ៖ អីចឹងប្រជាជនធម្មតាមមិនភ័យស្លាប់ហើយ?

មុំត ៖ ទេ ប្រជាជនធម្មតាភ័យដែរបើចាប់ចង១ចឹង ។

ឈុនលី ៖ ប្រហែលប៉ុន្មាននាក់ដែលមីងឃើញ?

មុំត ៖ ប្រហែលដប់នាក់ ម្នាក់ចេះតែចាប់ចងទៅណាស ហើយបងជីដូនមួយខ្ញុំទាហានបានបី ថ្ងៃគេចាប់ចងទៅណាស ចាប់ចងយកទៅវ៉ៃនៅអារក្សបាក់ករ ។

ឈុនលី ៖ បងមីងបង្កើត?

មុំត ៖ អត់ទេបងជីដូនមួយ ។

ឈុនលី ៖ គាត់ទើបតែធ្វើទាហាន?

មុំត ៖ ធ្វើទាហានបានតែបីថ្ងៃ ។

ឈុនលី ៖ គាត់ធ្វើទាហានអីគេ?

មុំត ៖ ទាហាននៅជប់យើងហ្នឹង ។

ឈុនលី ៖ ទាហានខាងណាវិញ?

មុំត ៖ ទាហានមិនដឹងខាងណាទេតែយើងមិនទាន់បានទៅវ៉ៃទៅអីទេទើបតែចូលទៅក៏អាពតវាចូល មកក៏ចេញមកវិញតែជាប់បានបីថ្ងៃធ្វើបានបីថ្ងៃ ។ ឪពុកខ្ញុំគាត់ភ័យណាស់គេបញ្ជូរទៅណា ក៏ទៅ ។

ឈុនលី ៖ ចឹងអ្នកផ្សេងទៀតដែលអត់ជាប់ប្រវត្តិរូបគេកត់សារថ្មី?

មុំត ៖ ហ្នឹងហើយគេកត់សារថ្មី ។

ឈុនលី ៖ កត់ពេលហ្នឹងម៉ង?

មុំត ៖ អ្នកណាល្អអ្នកណាអាក្រ់ ។

ឈុនលី ៖ មីងឃើញគេចាប់ហ្នឹងចាប់ដាក់ឡាន?

មុំត ៖ គេចាប់ចង១ទៅ ។

ឈុនលី ៖ ប្រហែលប៉ុន្មាននាក់ទៅ?

ម៉ុត ៖ ប្រហែលដប់ម្ភៃនាក់ ដល់តែយើងអ្នកដែលមិនជាប់ចំណងជាប់អីគេយកយើងទៅទុកនៅលើភ្នំ ។

ឈុនលី ៖ ភ្នំអី?

ម៉ុត ៖ ភ្នំជញ្ជាំងនេះណាស គេឲ្យទៅនៅជើងភ្នំរួចដល់តែយើងពួកអ្នកចាប់ចងនេះណាសគេដាក់ឡានបើកទៅចេះទៅភូមិខ្ញុំនេះណាស តាមថ្នល់ជាតិចឹងទៅគេហៅពួកសេនាជនគេហៅកញ្ច្រោវទៅណាស ហើយអ្នកជាប់ចំណងក៏នៅលើឡានដឹកទៅចេះទៅអារក្សបាក់ករ ។

ឈុនលី ៖ ដឹងតែសម្លាប់ហើយ?

ម៉ុត ៖ ដឹងតែសម្លាប់ហើយតែប៉ុណ្ណឹងហើយដឹងតែវ៉ៃចោលហើយ រួចទៅឡើងស្ងាត់ជ្រាបម៉ាផ្ទះៗស្ងាត់អត់មានអ្នកណាហ៊ានដើរទេមានតែសេនាជន យោធាទេកាលនោះគេហៅឈ្លបឈ្លបភូមិឈ្លបអីអ្នកដើរធ្វើការឲ្យគេ ថាស្ងាត់ជ្រាប ប្រជាជនស្ងាត់ជ្រាបអត់មានអ្នកណានៅទេ ។ ហៅទៅធ្វើការជីរះស្មៅកាលនោះខ្ញុំនៅតូចៗគេជីរះស្មៅគេដាំដំឡូង អង្ករគេចែកមិនដល់ម៉ាកំប៉ុងផង ។

ឈុនលី ៖ អាហ្នឹងធ្វើការនៅឯណាវិញ?

ម៉ុត ៖ ធ្វើការនៅនោះឯងនៅភូមិនោះឯងគេដាំដំឡូង ជីរះស្មៅ ។

ឈុនលី ៖ មីងទៅនៅហ្នឹងភូមិអីគេ?

ម៉ុត ៖ ដែលខ្ញុំនៅនោះហ្អី?

ឈុនលី ៖ ដែលមីងថាគេមកដំបូងធ្វើប្រវត្តិរូបសារថ្មីហើយគេយកទៅឲ្យធ្វើការហ្នឹងនៅឯណា?

ម៉ុត ៖ នៅនោះឯងនៅគោកលន់ ។

ឈុនលី ៖ នៅគោកលន់?

ម៉ុត ៖ ចាស ។

ឈុនលី ៖ ភូមិគោកលន់?

ម៉ុត ៖ ភូមិគោកលន់ ។

ឈុនលី ៖ នៅកន្លែងភ្នំជញ្ជាំ?

ម៉ុត ៖ ភ្នំជញ្ជាំងអត់បាននៅទេ នៅគោកលន់ ព្រឹកឡើងគេហៅជីរះស្មៅទៅ គេដាំដំឡូង ។

ឈុនលី ៖ ហើយគេឲ្យយើងស្នាក់នៅម៉េចទៅ?

ម៉ុត ៖ ទេ ស្នាក់នៅនឹងផ្ទះយើងមានផ្ទះស្នាក់នៅផ្ទះហើយ ។

ឈុនលី ៖ ខ្ទមហ្អី?

ម៉ុត ៖ មានផ្ទះនៅគោកលន់មានផ្ទះក៏ព្រឹកឡើងទៅធ្វើការដាំដំឡូង ដំរះស្មៅ អ្នកណាទៅស្រែក៏ទៅៗ ។ កុមាគេឲ្យទៅកាប់ទន្រ្ទានខែត្រធ្វើដីធ្វើអីណាស កុមារៗកាប់ទន្រ្ទានខែត្រយើងនោះណាស ។

ឈុនលី ៖ ចុះមីងនៅហ្នឹងយូរ ហើយហូបបាយយ៉ាងម៉េចទៅ?

ម៉ុត ៖ បាយនោះអង្ករគេចែកឲ្យម៉ាគ្រួសារពីរកំប៉ុង ។

ឈុនលី ៖ ម៉ាថ្ងៃ?

ម៉ុត ៖ ម៉ាថ្ងៃ ។

ឈុនលី ៖ ហើយគ្រួសារមីងប៉ុន្មាននាក់?

ម៉ុត ៖ នៅនោះតែប្រាំប្រាំមួយនាក់ប៉ុណ្ណោះឯងពុកខ្ញុំម៉ែខ្ញុំ ប្រាំប្រាំមួយនាក់ហ្នឹងគេឲ្យពីរកំប៉ុង បើគ្រួសារច្រើនគេឲ្យបួនកំប៉ុងប្រាំកំប៉ុង បើគ្រួសារតិចគេឲ្យបីកំប៉ុង ។ ខ្ញុំ ពុកខ្ញុំម៉ែខ្ញុំពីរកំប៉ុងហូបម៉េចឆ្អែតគ្នាប្រាំនាក់ពីរកំប៉ុង ។

ឈុនលី ៖ ចុះម៉ាថ្ងៃប៉ុន្មានកំប៉ុងទៅ?

ម៉ុត ៖ ម៉ាថ្ងៃយើងស៊ីម៉ាកំប៉ុង ព្រឹកម៉ាកំប៉ុងល្ងាចម៉ាកំប៉ុង ។

ឈុនលី ៖ បបរទៅ?

ម៉ុត ៖ បបរ ខ្ញុំដាក់ម៉ាទូកដៃហើយទឹកដាក់ម៉ាឆ្នាំង អាឆ្នាំងយើងប៉ុណ្ណេះទៅខ្ញុំដាក់ចំហុយវាស់ព្រឹកចំហុយទៅក៏វារីកឡើងកាចឆ្នាំង ម៉ែខ្ញុំមួយប្អូនខ្ញុំមួយ ។

ឈុនលី ៖ អត់ដាក់បបរទេ?

ម៉ុត ៖ ទេ ចំហុយឲ្យវារីង បបរវាភាវពេកចឹងយើងបេះស្លឹកឈើស្លឹកព្រៃ ក្តិលចេក ល្ហុងហើយស្អីនៅក្នុងព្រៃ ឬអាណោ ។

ឈុនលី ៖ អាណោយ៉ាងម៉េច?

ម៉ុត ៖ អាណោនៅក្នុងព្រៃណាស នាងឯងមិនស្គាល់ទេ នៅក្នុងព្រៃជីកមកយកមកកោសហើយពូតៗដាក់ដាំចំហុយទៅ អំបិលក៏មិនមាន ។ អំបិលចែកគ្នាម៉ាចុងស្លាបព្រា កំសត់ណាស នាងមិនចង់និយាយទេវេទនាណាស់ ទៅលើកទំនប់ក៏វេទនាដែរ ។

ឈុនលី ៖ គោកលន់ហ្នឹងចឹងគេធ្វើជារបៀបភូមិហ្អីបានឲ្យយើងទៅនៅ?

ម៉ុត ៖ ភូមិ ម៉ាភូមិមានគេនៅ ។

ឈុនលី ៖ ចឹងអ្នកនៅគោកលន់ហ្នឹងអត់មានទៅណាទេចឹង?

មុំត ៖ មានទៅណាគោកលន់គេនៅគោកលន់នោះ ជម្លៀសតែខ្ញុំទៅ ។

ឈុនលី ៖ ចុះអ្នកផ្សេងទៀត?

មុំត ៖ គេនៅភូមិនេះឯង ខ្ញុំនៅភូមិនេះមកពីគោកយាវទៅនៅគោកលន់ ខ្ញុំនៅគោកលន់ ។

ឈុនលី ៖ ចឹងអត់ទាន់ជម្លៀសទៅណាទេ?

មុំត ៖ អត់ទាន់ទៅណាទេដល់នេះទើបតែជម្លៀសទៅនោះ ។

ឈុនលី ៖ ទៅធ្វើស្រែអីចឹងទៅ?

មុំត ៖ ទៅធ្វើស្រែ ។

ឈុនលី ៖ ស្ទូង ដក?

មុំត ៖ ចំការដាំត្រសក់ ឪឡឹក មានតែស្រែចំការហ្នឹងឯងអត់មានអីទេ ។

ឈុនលី ៖ ចុះពេលណាបានគេមានសហករណ៍?

មុំត ៖ សហករណ៍សម័យប៉ុល ពតនោះហ្អី?

ឈុនលី ៖ ចាស ។

មុំត ៖ សហករណ៍នៅតែរហូតហ្នឹង ។

ឈុនលី ៖ នៅគោកលន់ហ្នឹងនៅដាំបាយខ្លួនឯងហូបហ្នឹង?

មុំត ៖ ដាំបាយខ្លួនឯង ។

ឈុនលី ៖ ចុះកាលណាបានហូបបាយរួម?

មុំត ៖ អត់ទេ អត់មានបាយរួមទេទាល់តែខ្ញុំជម្លៀសមកវិញហើយ មាខ្ញុំជម្លៀសមកវិញនៅដក់ពរ ។

ឈុនលី ៖ ដក់ពរ?

មុំត ៖ នេះដក់ពរតាមផ្លូវនេះ ។

ឈុនលី ៖ ដក់ពរ?

មុំត ៖ ដក់ពរ ។

ឈុនលី ៖ ភូមិហ្អី?

មុំត ៖ ភូមិនៅតាមថ្នល់ ។

ឈុនលី ៖ ដក់ពរ ពូរបស់មីងគាត់ធ្វើអីបានទៅយកមកបាន?

មុំត ៖ មានធ្វើអី ម៉ែខ្ញុំគាត់ចាស់ហើយ គាត់ងងឹតងងល់ពេកក៏គាត់ទៅយកមកនៅឯណោះមកនៅដក់ពរជុំគ្នាម៉ែខ្ញុំ ។

ឈុនលី ៖ ពូហ្នឹងទៅសុំគេហ្អី?

ម៉ុត ៖ ទៅសុំគេ បងខ្ញុំទៅសុំគេមកនៅជាមួយ ។

ឈុនលី ៖ ពូឬបង?

ម៉ុត ៖ បង ។

ឈុនលី ៖ មិនមែនពូទេ ។

ម៉ុត ៖ ទេ បងដែលមកមិញ ។

ឈុនលី ៖ គាត់ទៅសុំគេឲ្យមកនៅ?

ម៉ុត ៖ មកនៅឯណេះជាមួយបងខ្ញុំ ។

ឈុនលី ៖ នៅភូមិដក់ពរ?

ម៉ុត ៖ ចាស!

ឈុនលី ៖ គាត់មានគ្រួសារហ្អី?

ម៉ុត ៖ អត់ ។

ឈុនលី ៖ ចុះម៉េចបានមកនៅជាមួយគាត់កើត?

ម៉ុត ៖ ទេ បងខ្ញុំមាន គាត់មានគ្រួសារ មានប្ដីនោះណាស ។

ឈុនលី ៖ ហើយមកនៅជុំគ្នា?

ម៉ុត ៖ នៅជុំគ្នា ។

ឈុនលី ៖ ហើយហូបចុកម៉េចទៅ?

ម៉ុត ៖ ហូបចុកក៏គេឲ្យបើកបបរក្នុងម៉ាគ្រួសារសិតទៅបានម៉ាស្លាបព្រា សហករណ៍គេបបរឲ្យ ។

ឈុនលី ៖ ពេលណាបានមកធ្វើសហករណ៍?

ម៉ុត ៖ មកនៅនេះ ។

ឈុនលី ៖ ធ្វើយូរទេសហករណ៍?

ម៉ុត ៖ យូរបានគេធ្វើ ។

ឈុនលី ៖ យូរប៉ុណ្ណាទៅ ចូលឆ្នាំណាបានរៀបសហករណ៍?

ម៉ុត ៖ គេរៀបតាំងពីមុនតែខ្ញុំទើបតែមកនៅក៏បាយរួម មានតែបបរមិនដែលមានបាយទេ ។

ឈុនលី ៖ ចឹងពេលមីងមកនៅហ្នឹងគេរៀបសហករណ៍ហើយៗ?

ម៉ុត ៖ រៀបហើយៗ ដាក់ឲ្យរួចអស់ហើយ ។

ឈុនលី ៖ ចុះមីងធ្វើការអី?

ម៉ុត ៖ មានធ្វើការអី ។

ឈុនលី ៖ គេឲ្យធ្វើអីខ្លះ?

ម៉ុត ៖ គេឲ្យទៅស្រែ ជីវះស្មៅដំឡូងទាល់តែខ្ញុំអាយុ១៥បានចេញ ។

ឈុនលី ៖ ម៉េច១៥បើកាលនោះមីងម្ដេហើយហ្នឹង?

ម៉ុត ៖ ខ្ញុំថាមិនទាន់ដល់ម្ដៃ ។

ឈុនលី ៖ ចុះបើឥឡូវ៥២ហើយ!

ម៉ុត ៖ យូរពេកវាភ្លេចភ្លាំងហើយភ្លេចច្រើន បានខ្ញុំទៅចេញចល័តរហូតហើយអត់នៅភូមិទេ ។

ឈុនលី ៖ ចឹងគេមានសហករណ៍ចឹងមីងធ្វើការដាំចំការ?

ម៉ុត ៖ ដាំចំការអីរួចខ្ញុំឈប់នៅភូមិហើយ ។

ឈុនលី ៖ ដាំចំការអីវិញអាហ្នឹង?

ម៉ុត ៖ ចំការដំឡូង ចំការត្រសក់ ឪឡឹកអីចេះតែដាំទៅណាស តែនេះខ្ញុំឈប់ហើយខ្ញុំឈប់នៅភូមិហើយ ។

ឈុនលី ៖ មកនៅយូរទេនៅភូមិហ្នឹង?

ម៉ុត ៖ នៅដក់ពរ?

ឈុនលី ៖ ចាស

ម៉ុត ៖ នៅយូរហើយនៅដល់ពេលសន្តិភាព ។

ឈុនលី ៖ នៅបានប៉ុណ្ណាបានទៅលើកទំនប់?

ម៉ុត ៖ នៅបានប្រហែលម៉ាខែប៉ុណ្ណោះឯង ម៉ាខែបានគេចេញរហូតចេញចល័តរហូត ។

ឈុនលី ៖ ទៅនៅកងចល័ត?

ម៉ុត ៖ ចាស កងចល័តរហូត ។

ឈុនលី ៖ ចល័តជាមួយអ្នកណា?

ម៉ុត ៖ ជាមួយគ្រូរស់ ជាមួយ...ភ្លេចអស់បាត់ហើយ ។

ឈុនលី ៖ ជាមួយអ្នកនៅក្នុងភូមិនេះដែរហ្អី?

ម៉ុត ៖ ទេ អ្នកភូមិនេះមិនដែលបាននៅជាមួយទេ ។

ឈុនលី ៖ និយាយថាអ្នកភូមិដក់ពរហ្នឹង?

ម៉ុត ៖ ហ្អស!មិនសូវមានទេ ។

ឈុនលី ៖ ចុះមីងទៅជាមួយអ្នកណា?

មុ៉ត ៖ ទៅជាមួយអ្នកនៅភ្នំលាភ អ្នកស្រុកឡោទ័យ អ្នកស្រុកប៉ុស្ដិ៍ចាស់ ។

ឈុនលី ៖ ហើយគេប្រាប់ថាម៉េច?

មុ៉ត ៖ ប្រាប់ទៅលើកទំនប់ ។

ឈុនលី ៖ គេដើរប្រមូលតាមផ្ទះ?

មុ៉ត ៖ ប្រមូលតាមផ្ទះនារីយុវជនទៅទាំងអស់គ្នាអត់មាននៅទេ ។

ឈុនលី ៖ លើកទំនប់អី?

មុ៉ត ៖ លើកទំនប់អី លើកទំនប់ត្រពាំងថ្ម ។

ឈុនលី ៖ ដំបូងគេហ្នឹងទៅត្រពាំងថ្ម?

មុ៉ត ៖ ទៅត្រពាំងថ្ម នែ!ស្ពានស្រែង ស្ពានស្រែងរួចកូនខ្វែង ។

ឈុនលី ៖ មិនមែនចេញពីត្រពាំងថ្មទេ?

មុ៉ត ៖ ហួស!ស្ពានរាប ។

ឈុនលី ៖ ស្ពានរាបរួចកូនខ្វែង?

មុ៉ត ៖ ស្ពានរាបរួចកូនខ្វែង រួចទៅដំបូកបី ។

ឈុនលី ៖ ដំបូកបីនៅឯណាអីចេះ?

មុ៉ត ៖ ដំបូកបីនៅជិតព្រៃមាន់ ។

ឈុនលី ៖ ភូមិហ្អី?

មុ៉ត ៖ មានភូមិអីណាកណ្ដាលវាលហ្នឹង ព្រៃមាន់ហ្នឹងលើកព្រៃមាន់រួចរន្ទះបាញ់ វាលដង្កៀបក្ដាមផង ។

ឈុនលី ៖ ហើយទៅណាទៀត?

មុ៉ត ៖ អស់ហើយ បើនៅក្បែរបត់ត្រង់នោះអត់បានលើកទេ ។

ឈុនលី ៖ ចាំខ្ញុំសួរមីងម៉ាតន្ទាក់ៗវិញណាស?

មុ៉ត ៖ ចាស!

ឈុនលី ៖ ចុះអាកាលទៅត្រពាំងថ្មដំបូងហ្នឹងស្ថានភាពយ៉ាងម៉េចខ្លះ?

មុ៉ត ៖ មានម៉េច មានតែលើកទំនប់ហ្នឹងហើយ ។

ឈុនលី ៖ ត្រពាំងថ្មហ្នឹងគេធ្វើដើម្បីអី?

មុ៉ត ៖ គេធ្វើលក្ខខ័ណគេធ្វើជាអាងទុកសំរាប់លេង ពួកអ្នកមកពីណាៗអ្នកធ្វើការអ្នកធំៗគេទៅមើល ។

ឈុនលី ៖ ទុកតែមើលទេអត់មានទុកធ្វើស្រែទេ?

ម៉ុត ៖ ទុកធ្វើជាអាងឲ្យល្អមើល កាលមុនធ្វើស្រែ គេធ្វើស្រែផង ។

ឈុនលី ៖ កាលនោះណាស ដែលគេប្រាប់យើងគេថាទុកធ្វើអី?

ម៉ុត ៖ ទុកធ្វើស្រែយើងដាក់អាងមកទុកធ្វើស្រែប្រាំងស្រែវស្សាមិនដែលមានឈប់ណាស ។

ឈុនលី ៖ ហើយនៅហ្នឹងមានប្រជាជនច្រើនទេ?

ម៉ុត ៖ ហ៊ូស ច្រើនណាស់រាប់រយ ។

ឈុនលី ៖ រាប់រយហ្អឺម៉ឺន?

ម៉ុត ៖ រាប់ម៉ឺន ។

ឈុនលី ៖ ភាគច្រើនស្រីឬប្រុស?

ម៉ុត ៖ ទាំងស្រីទាំងប្រុស នារីយុវជន ទាំងចាស់ទាំងក្មេង អ្នកប្រជាជនថ្មីប្រជាជនចាស់អីទៅ ទាំងអស់មកពីខាងភ្នំពេញ កំពង់ចាម កំពង់ឆ្នាំងអីទៅទាំងអស់ជុំគ្នាជាពិសេសអ្នកថ្មីអ្នក ។

ឈុនលី ៖ មីងចាំទេនៅឆ្នាំណាប្រហែលៗទេ?

ម៉ុត ៖ យូរចេះទៅក៏ភ្លេច ឈឺផងអីផងវាភ្លេច ។

ឈុនលី ៖ គិតមើលទៅប្រហែលឆ្នាំណា៧៦ ៧៧?

ម៉ុត ៖ ៧៥ហ្អឺ?

ឈុនលី ៖ ៧៥ចូលដំបូងហ្នឹង?

ម៉ុត ៖ ៧៥ចូលដំបូង ចិតប៉ុន្មានទេភ្លេចអស់ហើយ បើខ្ញុំទៅកូនខ្វែងខ្ញុំចល័តរហូតខ្ញុំណាសមិន ដែលបាននៅម៉ាកន្លែងទេ ។ កូនខ្វែងអត់ទឹកម៉ាអាទិត្យ ។

ឈុនលី ៖ ចុះពេលទៅត្រពាំងថ្មហ្នឹងហូបចុកយ៉ាងម៉េច?

ម៉ុត ៖ ហូបចុកវាគ្រាន់ដែរគេវាល់បាយណាស បាយម៉ាចានៗប៉ុណ្ណេះ!

ឈុនលី ៖ ហូបជាមួយអី?

ម៉ុត ៖ ថ្ងៃណាទៅក៏ទឹកប្រហុកម៉ាស្លាបព្រាចែកគ្នាទៅមានស្អី ។

ឈុនលី ៖ មានទឹកហូបដែរ?

ម៉ុត ៖ ទឹកក៏ចែកគ្នាសំបូរណាសទៅខាងត្រពាំងថ្ម បើទៅខាងកូនខ្វែងចែកគ្នា ។

ឈុនលី ៖ សំបូរម៉េចទៅ ហូបម៉ាឆ្អែត?

ម៉ុត ៖ ហូបម៉ាឆ្អែតហើយយើងបានមុជបានអី?

ឈុនលី ៖ មានទឹកមុជទៀត?

ម៉ុត ៖ ទឹកមុជ យើងនៅត្រពាំងថ្មណាសមានខ្លះពីរបីថ្ងៃយើងមុជខ្លះ បើយើងទៅកូនខ្វែងវិញមិនមានទេ ។

ឈុនលី ៖ មីង ខ្ញុំសុំសួរកន្លែងត្រពាំងថ្មបន្តិច កន្លែងនោះមានទឹកហូបគ្រប់គ្រាន់?

ម៉ុត ៖ មាន ។

ឈុនលី ៖ ទឹកមកពីណា?

ម៉ុត ៖ ទឹកដែលគេជីកអាងដែលគេធ្វើបានហើយដែលគេជីកទៅវាចេញមកក៏យើងដើរជីកតាមស្រុកតាមអីដែលគេនៅក៏យើងទៅដងទៅ ។

ឈុនលី ៖ ទៅដងខ្លួនឯងមិនមែនគេដងយកមកចែកទេ?

ម៉ុត ៖ គេដងបានគេយកមកចែក គេចាត់ម្នាក់ឲ្យទៅរកទឹកសំរាប់យកមកឲ្យផឹក ម្ញ៉ៃបានតែពីរដើងទេយកមកចែកគ្នាបានម្នាក់ម៉ាកាៗទៅ ។

ឈុនលី ៖ គេវាល់ស្លាបព្រាទេ?

ម៉ុត ៖ វាល់ វាល់ស្លាបព្រាតែនៅនេះមិនសូវដែលវាល់ទេម្នាក់ម៉ាកាៗ ។

ឈុនលី ៖ ម្ញ៉ៃ?

ម៉ុត ៖ ទេ ផឹកអស់បើស្រេកទៀតក៏ ថាម្ញ៉ៃទៅចោះបើមិនបានមកទៀតថាវាឆ្ងាយ ។

ឈុនលី ៖ ហើយគេជីកហ្នឹងគេចែកប៉ុន្មានម៉ែត្រៗ?

ម៉ុត ៖ គេបែងចែកបើកំលាំងទីមួយហ្នឹងបីម៉ែត្រគីប ។

ឈុនលី ៖ បីម៉ែត្រគីបហ្នឹងអាហ្នឹងទទឹងបណ្ដោយទទឹងប៉ុន្មាន?

ម៉ុត ៖ ទទឹងពីរម៉ែត្រ បណ្ដោយបីម៉ែត្រ ។

ឈុនលី ៖ ជំរៅ?

ម៉ុត ៖ ជំរៅកន្លះម៉ែត្រ ។

ឈុនលី ៖ ចែកប៉ុណ្ណឹង?

ម៉ុត ៖ ចែកប៉ុណ្ណឹង ។

ឈុនលី ៖ ម្នាក់?

ម៉ុត ៖ ចាស ម្នាក់ ។

ឈុនលី ៖ ហើយគេចែកតាមក្រុម?

ម៉ុត ៖ ចាស គេចែកតាមក្រុមម៉ាក្រុមដប់នាក់ ។

ឈុនលី ៖ ដប់នាក់មិនសាបសិបម៉ែត្រហើយ?

ម៉ុត ៖ ហ្នឹងហើយសាមសិបម៉ែត្រ ។

ឈុនលី ៖ ហើយមីងលើករួចដែរបីម៉ែត្រ?

ម៉ុត ៖ ខ្ញុំមិនបានលើករួចទេ ខ្ញុំកំលាំងទីពីរ ។

ឈុនលី ៖ កំលាំងទីមួយប្រភេទម៉េច?

ម៉ុត ៖ កំលាំងទីមួយគេកំលាំងធំណាស មាឌធំៗ ។

ឈុនលី ៖ ប្រុសឬស្រី?

ម៉ុត ៖ ទាំងប្រុសទាំងស្រី ។

ឈុនលី ៖ ហើយខុសគ្នាយ៉ាងម៉េចទី១ទី ២ហ្នឹង?

ម៉ុត ៖ អាកំលាំងទីមួយវាខ្សោយណាស លើកបីម៉ែត្រមិនរួចហើយយើងតែពីរម៉ែត្រគីប ។

ឈុនលី ៖ ចុះធ្វើម៉េចដឹងបើទៅដំបូងទាំងអស់គ្នា?

ម៉ុត ៖ ទេ ដឹងគេដឹងប្រធានកងគេអ្នកដើរនេះគេដឹង ។ ដូចខ្ញុំលើកតែពីរម៉ែត្រគីប ពីរម៉ែត្រគីប អាអីចេះពីរម៉ែត្រ អាបណ្ដោយចេះវាម៉ាម៉ែត្រ ។

ឈុនលី ៖ អាពីរម៉ែត្រគីបហ្នឹងទទឹងប៉ុណ្ណានម៉ែត្រ?

ម៉ុត ៖ ទទឹងពីរម៉ែត្រ ។

ឈុនលី ៖ បណ្ដោយ?

ម៉ុត ៖ បណ្ដោយម៉ាម៉ែត្រ ហួស!ទទឹងម៉ាម៉ែត្រ បណ្ដោយពីរម៉ែត្រ ជំរៅកន្លះម៉ែត្រ វាចេះតែភ្លេចទៅណាស ខ្ញុំលើករួច ។

ឈុនលី ៖ ម្ល៉េលើករួច?

ម៉ុត ៖ រួច គេអ្នកខំតែម៉ោងដប់ ម៉ាគាដប់រួចហើយ ។

ឈុនលី ៖ ដប់អីគេដប់យប់ឬដប់ព្រឹក?

ម៉ុត ៖ ដប់ព្រឹកណាស ព្រឹកឡើងលើកហើយ ។

ឈុនលី ៖ ចុះល្ងាចឡើងទំនេរធ្វើអី?

ម៉ុត ៖ ល្ងាចឡើងទៅក៏យើងនៅកន្លែងដែលយើងលើកម៉ែត្រគីបហើយ ។

ឈុនលី ៖ មីងលើកហើយម៉ោងដប់ព្រឹក?

ម៉ុត ៖ ទេថ្ងៃណាទៅឡើងម៉ោងបីបានរួច ។

ឈុនលី ៖ ដែលដល់យប់ទេ?

ម៉ុត ៖ ដល់យប់ថ្ងៃណាដែលខ្ពស់ណាសដែលខ្ញុំលើកនៅស្ពានរាបវាខ្ពស់ណាស ។ លើករួចក៏យើងឈប់សំរាកទៅម៉ោងបី ។ ខ្ញុំមិនសូវដែលលើកទេយប់តែម៉ោងបីខ្ញុំរួចហើយ ។

ឈុនលី ៖ រួចហើយទៅណា?

ម៉ុត ៖ រួចហើយទៅរកទឹករកភក់ ទឹកមុជទឹកដឹកគេមិនដែលថាអីយើងទេដែលយើងរួចហើយប្រធានកង...

ឈុនលី ៖ ប្រធានកងរបស់មីងអ្នកណាគេ?

ម៉ុត ៖ មិនចាំទេ ប្រធានកងរបស់ខ្ញុំ គ្រូរស ។

ឈុនលី ៖ ឈ្មោះរស់ហ្អីប្រធានកងរបស់មីង?

ម៉ុត ៖ ចាស!

ឈុនលី ៖ មាកងប៉ុន្មាននាក់?

ម៉ុត ៖ ម៉ារយហើយ ។

ឈុនលី ៖ គារស់ ហ្អី?

ម៉ុត ៖ ចាស!

ឈុនលី ៖ ប្រុស?

ម៉ុត ៖ ចាស គ្រូរស់ ។

ឈុនលី ៖ ឈ្មោះអីគេ?

ម៉ុត ៖ មិនដឹងឈ្មោះអីគេទេ ។

ឈុនលី ៖ នៅដែររាល់ថ្ងៃ ។

ម៉ុត ៖ នៅគាត់នៅបង្ហាត់សិស្សរាល់ថ្ងៃ ។

ឈុនលី ៖ មេកង គាត់អ្នកចាត់ចែងនៅត្រពាំងថ្មហ្នឹង?

ម៉ុត ៖ ចាត់ គេស្នើគាត់ទៅ គាត់នាំទៅលើក ។

ឈុនលី ៖ ចុះមេបស់គារស់ទៀតឈ្មោះអី មេធំ?

ម៉ុត ៖ មេគាត់ឈ្មោះអីទេ...

ឈុនលី ៖ តាវ៉ាល់ហ្អី?

ម៉ុត ៖ ទេ មិនបាននៅនឹងតាវ៉ាល់ទេ ។

ឈុនលី ៖ យាយចែម?

ម៉ុត ៖ ទេ នៅមិនទាន់ យាយចែម ទេ ។

ឈុនលី ៖ តាម៉ោង?

ម៉ុត ៖ តាម៉ោងក៏មិនបានមក ។

ឈុនលី ៖ តាម៉ុត?

ម៉ុត ៖ តាម៉ុត ក៏មិនបានមក ។

ឈុនលី ៖ ស្រី ឬប្រុស?

ម៉ុត ៖ មិនដឹងឈ្មោះអី ស្រអែម ឈ្មោះស្រអែមចឹងហ្អីដែលប្រធានកងខ្ញុំវរៈឈ្មោះស្រអែម ស្រី ឈ្មោះបងអែម ។

ឈុនលី ៖ មេតារស់ ទៀត?

ម៉ុត ៖ ហ្នឹងហើយក្តាប់ទាំងអស់ម៉ាកងធំប៉ុន្មានកងធំវាបីរយ បីរយនាក់ណាស ឈ្មោះបងអែម ចឹងហើយហ្អាស ឈ្មោះបងអែម ក្មេចឈ្មោះផងដែលយូរទៅវាឈឺអីផង ។ ឈ្មោះ អែម ហ្នឹងឯង ។

ឈុនលី ៖ ចុះគណៈតំបន់មីងស្គាល់ទេ?

ម៉ុត ៖ គណៈតំបន់មានអីណា មានតែ តាវ៉ាល់ តាម៉ោង ។

ឈុនលី ៖ តាម៉ោង ហ្អីតាមោង?

ម៉ុត ៖ តាម៉ោង តាវ៉ាល់ ។

ឈុនលី ៖ តាវ៉ាល់ ហ្នឹងមេធំ មេតំបន់ហ្អី?

ម៉ុត ៖ មេដំបន់ ។

ឈុនលី ៖ កាចទេ?

ម៉ុត ៖ ទេ បើមិនដែលបានជួបផង ។

ឈុនលី ៖ តាវ៉ាល់ ហ្នឹងនៅឯណា?

ម៉ុត ៖ មិនដឹងនៅខាងណា ខ្ញុំមិនដែលបាននៅជុំគាត់ផងនៅតែជាមួយប្រធានកងៗ គាត់មិនសូវ ចុះទេ ជួនណាចុះទៅណុង នែ!ម្តងចុះទៅប្រពាំងថ្ម យូរៗចុះទៅម្តងទៅត្រួតមើលម្តង ។

ឈុនលី ៖ ចុះទៅម្តងៗដែរ?

ម៉ុត ៖ ចុះទៅម្តងៗ បើខ្ញុំមិនដែលបានឃើញផងខ្ញុំនៅតែចល័តរហូត ។

ឈុនលី ៖ មីងនៅត្រពាំងថ្មយូរដែរ?

ម៉ុត ៖ យូរហើយ ។

ឈុនលី ៖ នៅប៉ុន្មានខែ?

ម៉ុត ៖ នៅប្រហែលបានពីរខែ ។

ឈុនលី ៖ មុជទឹកបានច្រើនដងដែរ?

ម៉ុត ៖ មានអីសំណាំដែរតើយាប់តែនៅឯណោះទេវាឆ្ងាយ ។

ឈុនលី ៖ ពីរបីខែដែរ?

ម៉ុត ៖ ពីរបីខែ ។

ឈុនលី ៖ មីងដឹងទេថាអ្នកណាអ្នកនាំគំនិតធ្វើអាងត្រពាំងថ្មហ្នឹង?

ម៉ុត ៖ មានអ្នកណាមានតែពួក តាវ៉ាល់ តាម៉ោងហ្នឹង ។

ឈុនលី ៖ តាវ៉ាល់ តាម៉ោងអ្នកធ្វើ?

ម៉ុត ៖ ហ្នឹងហើយ មិនដឹងគាត់ទៅខាងណាអស់ហើយ ។

ឈុនលី ៖ ចុះមានអ្នកណាគេទៀតអ្នកគូសប្លង់គូសអីត្រឹមត្រូវទេ?

ម៉ុត ៖ គូសប្លង់ឲ្យលើក ។

ឈុនលី ៖ អ្នកណាអ្នកគូស?

អម៉ុត ៖ មិនដឹងអ្នកណាទេ បើខ្ញុំកមិនចាំ យូរហើយភ្លេចអស់មិនដែលទៅចងចាំរឿងហ្នឹងទេ ។

ឈុនលី ៖ រួចហើយចេញទៅណាទៀត?

ម៉ុត ៖ មានចេញទៅណា ចេញទៅលើកនៅនោះទៀត នៅស្ពានរាបស្ពានអី ។

ឈុនលី ៖ ស្ពានរាបហ្នឹងជាប់ជាមួយ...

ម៉ុត ៖ ស្ពានរាបជាប់ជាមួយស្ពានស្រែង ទៅពីត្រពាំងថ្មដែរ ។

ឈុនលី ៖ ធំទេ?

ម៉ុត ៖ ធំហើយ ខ្ពស់ បើខ្នងឡើង៥ម៉ែត្រ កំពស់ឡើងនោះជិតស្មើចុងដូង ។

ឈុនលី ៖ អាហ្នឹងនៅស្ពានរាប?

ម៉ុត ៖ ចា៎!

ឈុនលី ៖ ចុះត្រពាំងថ្មកំពស់ប៉ុន្មាន?

ម៉ុត ៖ ត្រពាំងថ្មក៏កំពស់ជិតស្មើនេះដែរ ស្មើនេះហើយត្រពាំងថ្ម ។

ឈុនលី ៖ ប្រហែលប៉ុន្មានម៉ែត្រដែរ?

ម៉ុត ៖ មិនដឹងប៉ុន្មានម៉ែត្រ មិនដល់ដប់ម៉ែត្រទេ វែកឡើងអីចេះហើយ ឡើងស្មើតឡើងទៅចាក់ប្រធានកងក៏គេនៅលើទំនប់ ។

ឈុនលី ៖ ទំនប់ត្រពាំងថ្មដល់គេធ្វើហើយទទឹងបណ្ដោយប៉ុន្មានដែរ?

មុំត ៖ ខ្ញុំមិនដឹងផង បើខ្ញុំមិនដែលឃើញ ។

ឈុនលី ៖ ឆ្ងាយហ្អី ត្រពាំងធំទេ?

មុំត ៖ ធំហើយបើខ្ញុំមិនដែលបានទៅឃើញផង ។

ឈុនលី ៖ ចុះអាកាលរួចហើយហ្នឹងណាស?

មុំត ៖ កាលលើករួចធំហើយ មើលទៅដាច់កន្ទុយភ្នែក ល្ងឹងល្ងើយមិនដឹងប៉ុន្មានគីឡូទេខ្ញុំវាភ្លេចទៅណាស ។

ឈុនលី ៖ មានតែដាំងដប់?

មុំត ៖ មិនដឹងប៉ុន្មានគីឡូ ខ្ញុំវាភ្លេច យូរទៅវាភ្លេច ខ្ញុំល្ងួងឈឺផងភ្លេចហើយមិនដែលសួរគិតគូមិនដែលមានគេមកសំភាសន៍អីចឹងផង ខ្ញុំមិនដែលដឹងភ្លេចអស់ហើយប៉ុន្មានឆ្នាំហើយមិនដឹងទទឹងប៉ុន្មានបណ្តោយប៉ុន្មាន ។

ឈុនលី ៖ នៅស្ពានរាបហ្នឹងហើយហូបចុកយ៉ាងម៉េចទៅ?

មុំត ៖ ហូបចុកហ្នឹងធម្មតាបាយវាល់ចែកគ្នាម៉ាចានៗ បបរទេណាស មិនមែនបាយទេ បបរឈ្មោលអារាងរីងៗតិចៗម្នាក់ម៉ាចាន ។

ឈុនលី ៖ ឆ្អែតទេ?

មុំត ៖ ម៉េចនឹងឆ្អែត ស្លឹកឈើស្លឹកព្រៃពួកអ្នកថ្មីផងបោចតែស្លឹកឈើស្លឹកព្រៃដាក់ ម៉ាចានប៉ុណ្ណេះឯង ។

ឈុនលី ៖ ដល់ពេលមីងទៅធ្វើការនៅត្រពាំងថ្មឃើញមនុស្សស្លាប់ទេ?

មុំត ៖ ដែលអត់ហ្អាស ។

ឈុនលី ៖ ស្លាប់ដោយសារអី?

មុំត ៖ ដូចយើងខុសសីលធម៌ខុសអីចឹង ដូចថាយើងមានប្រវត្តិថាយួនថាអីគេយកទៅវ៉ៃចោល ។

ឈុនលី ៖ និយាយថាអាពេលទៅធ្វើត្រពាំងថ្មហ្នឹងមានឃើញអ្នកណាធ្វើការៗស្លាប់ទេ?

មុំត ៖ ទេ មិនដែលសួរមានទេ មានតែខុសសីលធម៌ខុសអីហ្នឹង ។

ឈុនលី ៖ ខុសសីលធម៌ដែលយកទៅសំលាប់នៅមុខវត្តព្រះនេត្រព្រះហ្នឹង?

មុំត ៖ ហ្នឹងឯង ។

ឈុនលី ៖ មីងមកមើលដែរ?

មុំត ៖ មកមើល ។

ឈុនលី ៖ ហើយយ៉ាងម៉េចខ្លះទៅ?

ម៉ុត ៖ មានម៉េចគេវៃខ្លាកៗ ។

ឈុនលី ៖ អ្នកស្រុកណា?

ម៉ុត ៖ អ្នកស្រុកស្រែះ ។

ឈុនលី ៖ ស្រែះហ្អី?

ម៉ុត ៖ ស្រែះ គេវៃខ្លាកៗខុសសីលធម៌ ដូចពួកណាជាប់ប្រវត្តលោកធំលោកអីអ្នកធ្វើការពីសង្គមមិញគេយកទៅវៃចោល ។

ឈុនលី ៖ ចុះមានអ្នកណាក្រៅពីហ្នឹងទៀតទេ?

ម៉ុត ៖ អត់ទេ ។

ឈុនលី ៖ ចុះដែលមានអ្នកណាធ្វើការៗគេហៅយកទៅទេ?

ម៉ុត ៖ ប៉ះណាទៅក៏ធ្វើការសុខៗក៏គេហៅយកទៅដែរ អាហ្នឹងអ្នកជាប់ប្រវត្តិ ។

ឈុនលី ៖ មីងឃើញដែរ?

ម៉ុត ៖ ឃើញ គេចាប់ចងទៅ ។

ឈុនលី ៖ គេចាប់ចង ឃើញប៉ុន្មាននាក់ទៅ?

ម៉ុត ៖ ប៉ះណាពីរនាក់ ប៉ះណាទៅបីនាក់ ។

ឈុនលី ៖ អត់ស្គាល់ទេហ្អី?

ម៉ុត ៖ តែម៉េចស្គាល់ ។

ឈុនលី ៖ គេមកហ្នឹងសុទ្ធតែមានបញ្ជីត្រឹមត្រូវហ្អី?

ម៉ុត ៖ បញ្ជី ។

ឈុនលី ៖ គេកាន់មកហ្អី?

ម៉ុត ៖ គេកាន់មក ដែលគេដេញ គេមានឈ្មោះនេះឈ្មោះនោះ ។

ឈុនលី ៖ ខ្មែរក្រហមហ្អី?

ម៉ុត ៖ ពួកខ្មែរក្រហម ។

ឈុនលី ៖ ពួកហ្នឹងនិរតីហ្អី?

ម៉ុត ៖ ពួកនិរតី ។

ឈុនលី ៖ អាពេលមីងទៅលើកទំនប់ហ្នឹងពួកនិរតីហ្អីអ្នកកាន់កាប់?

ម៉ុត ៖ ពួកនិរតី ។

ឈុនលី ៖ ចុះ តាវ៉ាល់ អ្នកឯណាវិញ?

ម៉ុត ៖ តាវ៉ាល់ មិនដឹងឯណាមិនមែននិរតីទេ ។

ឈុនលី ៖ ពាយ័ព្យហ្អី?

ម៉ុត ៖ ពាយ័ព្យ តាវ៉ាល់ ហ្នឹងពាយ័ព្យទេបើពួកនេះនិរតី ។

ឈុនលី ៖ ចុះអាពេលដែលមីងទៅធ្វើនៅត្រពាំងថ្ម តាវ៉ាល់ ទៅមើលចឹងនៅគ្រប់គ្រងដោយពួកពាយ័ព្យនៅឡើយទេ ។

ម៉ុត ៖ យូរៗទៅម្ដងប៉ុណ្ណោះឯង ។

ឈុនលី ៖ ហើយដល់ពេលក្រោយមកពួកនិរតីទៅហ្នឹងបាត់ តាវ៉ាល់ ហ្នឹងមីងនៅហ្នឹងដែរ?

ម៉ុត ៖ នៅជាមួយពួកនិរតីដែរ ។

ឈុនលី ៖ នៅត្រពាំងថ្មហ្នឹងទៀត?

ម៉ុត ៖ នៅទៀត ធ្វើទាល់តែរួចត្រពាំងថ្ម ទាល់តែរួចត្រពាំងថ្មទៅដើរចល័តហើយគ្រប់កន្លែងខ្ញុំថាចល័តគ្រប់កន្លែងទៅស្ពានស្រែង ស្ពានរាប កូនខ្វែង ដំបូកបី ព្រៃមាន់ វាល់ដង្កៀបក្ដាម ។ វាលដង្កៀបក្ដាមកំពុងតែទៅដល់ អ្នកគ្រូអឺយកំពុងតែហូបបាយទៅពីនេះ ខ្ញុំទៅពីនេះ ទៅពីព្រៃមាន់ទៅក៏គេចាប់ភ្លាម ។

ឈុនលី ៖ ចាប់អ្នកណាគេ?

ម៉ុត ៖ គេចាប់ពួកគេថាយួន ខ្ញុំក៏គេនឹងចាប់ដែរ គេនឹងចាប់ថាយកទៅវ៉ៃចោល ។

ឈុនលី ៖ ចាប់ទាំងមីងទៀត?

ម៉ុត ៖ ហ្នឹងហើយ ក៏គ្រូខ្ញុំហ្នឹងហើយគ្រូរស់គាត់ប្រាប់ថា វាមិនបានយួនអីទេ ។ កាលនោះខ្ញុំដូចយួនបេះឯងវាសនោះវាជ្រះនោះ គេថាឯងយួន “វាមិនបានយួនអីទេ វាខ្មែរ” គេថាខ្ញុំរៀនដល់ថ្នាក់ទីបញ្ចប់កូនកុងសី ។ ខ្ញុំថាអត់ទេខ្ញុំមិនបានកុងសីអីទេ មីងខ្ញុំនេះឯងគ្រូរស់ហ្នឹងគាត់ថា “មិនបានកុងសីកុងអីទេ វាអ្នកស្រែតែម៉ែឪវាជ្រះក៏វាកាត់ មិនមែនយួនអីទេ” ទៅបានគេលែងខ្ញុំកុំអីស្លាប់បាត់ហើយ ។

ឈុនលី ៖ ភ័យទេមីង?

ម៉ុត ៖ ដែលមិនភ័យណាស ឃើញម៉ែឃើញឪ ។

ឈុនលី ៖ ដែលកំពុងធ្វើការៗហ្នឹងហ្អី?

ម៉ុត ៖ ទេ មិនទាន់ធ្វើការទេ បែកបាយ ។

ឈុនលី ៖ ពេលហូបបាយហ្អី?

ម៉ុត ៖ ចាស ពេលបែកបាយបែកសម្ល‌រទៅក៏...

ឈុនលី ៖ ស្មើណាទៅ?

ម៉ុត ៖ នៅវាលដង្កៀបក្ដាម ចែកបាយចែកសម្លទៅគេហៅទៅអ្នកគ្រូអឺយញ៉ូវដៃញ៉ូវជើង ។

ឈុនលី ៖ ប៉ុន្មាននាក់ទៅហៅ?

ម៉ុត ៖ ហៅពីរនាក់បីនាក់ពួកយោធា ។

ឈុនលី ៖ ពួកនោះមកពីណា?

ម៉ុត ៖ ពួកយោធា ។

ឈុនលី ៖ យោធាមកពីខាងណា?

ម៉ុត ៖ មកពីនោះឯងពាយ័ព្យយើងនេះឯង ។

ឈុនលី ៖ ស្គាល់ដែរអត់មីង?

ម៉ុត ៖ អត់ទេ មិនបានស្គាល់ទេ ។

ឈុនលី ៖ កាន់កាំភ្លើងមក?

ម៉ុត ៖ អត់កាន់កាំភ្លើង កាំភ្លើងគេស្រាប់សុទ្ធតែយោធា សេនាជន ។

ឈុនលី ៖ ហើយបានមីង គ្រូ?

ម៉ុត ៖ គ្រូរស់ ។

ឈុនលី ៖ ត្រូវជាមីងហ្អី?

ម៉ុត ៖ មីងខ្ញុំ មីងជីដូនមួយ បានខ្ញុំបានរស់កុំអីងាប់នឹងគេបាត់ហើយ ។

ឈុនលី ៖ ដោយសារមីងរស់ហ្នឹងផ្ញើមេកងផងហ្អីបាននិយាយទៅស្ដាប់គ្នា ។

ម៉ុត ៖ មេកងផងហើយគេឲ្យក្ដាប់ប្រធានកងតូច ។

ឈុនលី ៖ ហ្នឹងហើយដោយសារតែមីងរស់ហ្នឹងប្រធានកងផងទេហ្អីបានគេព្រមនោះ?

ម៉ុត ៖ ហ្នឹងហើយព្រោះខ្ញុំ លោកគ្រូគាត់ប្រាប់ផង លោកគ្រូរស់ប្រាប់ថាវាមិនមែនជាកូនកុងសីទេ ។

ឈុនលី ៖ គ្រូរស់ហ្នឹងមានពីរនាក់ហ្អី?

ម៉ុត ៖ គ្រូឡឹត ឈ្មោះគាត់មានពីរនាក់ គ្រូឡឹត និងគ្រូរស់ តែខ្ញុំហៅតែលោកគ្រូរស់ៗ ។

ឈុនលី ៖ មីងបស់មីងហ្នឹងឈ្មោះរស់ដែរ?

ម៉ុត ៖ ចា៎!នោះឯងៗ គ្រូនោះឯង ។

ឈុនលី ៖ អីចឹងតែម្នាក់ទេតើហ្អី គ្រូរស់ហ្នឹង?

ម៉ុត ៖ ចា៎! តែម្នាក់ហ្នឹងឯង មានពីរនាក់ឯណា គាត់នៅជាមួយខ្ញុំគាត់ប្រាប់ខ្ញុំ ខ្ញុំបានគ្រូរស់ហ្នឹង ឯងកុំអីខ្ញុំងាប់បាត់ហើយបានគាត់ថាគាត់ឆ្លើយទៅបានរួចមក ។

ឈុនលី ៖ ចឹងគេចាប់ប្រទ្បុំមនុស្សទេតើហ្អ៎?

ម៉ុត ៖ ចាប់ប្រទ្បុំ ។

ឈុនលី ៖ ប្រទ្បុំជាមួយអ្នកណាគេ?

ម៉ុត ៖ ឈ្មោះស្ដីទេ គេចាប់យកទៅវ៉ៃចោល ។

ឈុនលី ៖ ហើយដល់ពេលចឹងរួចពីហ្នឹងទៅណាទៀត?

ម៉ុត ៖ រួចទៅនៅនោះហើយ នៅលើកទំនប់ទាល់តែរួច ។

ឈុនលី ៖ លើកនៅឯណាទៀត?

ម៉ុត ៖ លើកនៅវាលដង្កៀបក្ដាម លើកំរួច ។

ឈុនលី ៖ ហើយចេញពីហ្នឹងទៅណាទៀត?

ម៉ុត ៖ ចេញពីនោះទៅៗនៅដើមគរបីដើម ។

ឈុនលី ៖ ដើមគរបីដើម ទៅនោះលើកទំនប់ទៀត?

ម៉ុត ៖ លើកទំនប់អីទៅដកស្នូងម្ដង ប្រូតកាត់អី សំរាកខ្លះ ។

ឈុនលី ៖ គរបីដើម?

ម៉ុត ៖ ចា៎!

ឈុនលី ៖ ហើយម៉េចទៀតទៅ យូរទេ?

ម៉ុត ៖ យូរឯណា តែម៉ាខែកន្លះខែទៅទៀត ។

ឈុនលី ៖ ទៅណាទៀត?

ម៉ុត ៖ លើកទំនប់ទៀត ។

ឈុនលី ៖ លើកនៅឯណាទៅ?

ម៉ុត ៖ លើកនៅស្ពានរាប ស្ពានស្រែងអី ។

ឈុនលី ៖ ស្ពានរាបហ្នឹងក្រែងនៅជិតត្រពាំងថ្មដែរ?

ម៉ុត ៖ នៅជិតគ្នាហ្នឹងហើយ ។

ឈុនលី ៖ ចុះម៉េចក៏ទៅមកៗចឹង?

ម៉ុត ៖ លើកបន្ដគ្នាបើថាដាច់ត្រង់ណាអីត្រង់ណាគេយកទៅដាក់ ។

ឈុនលី ៖ អីចឹងអាស្ពានរាបហ្នឹងនៅជិតត្រពាំងថ្មមែន ប៉ុន្តែមីងចេញពីប្រពាំងថ្មមកកន្លែងនេះសិន...

ម៉ុត ៖ ស្ពានស្រែង លើកបន្តពីស្ពានស្រែង ។

ឈុនលី ៖ ដង្កៀបក្ដាមហ្នឹ?

ម៉ុត ៖ ដង្កៀបក្ដាម ។

ឈុនលី ៖ ដង្កៀបក្ដាមហើយស្ពានស្រែងមួយណាលើកមុន?

ម៉ុត ៖ ដង្កៀបក្ដាមនៅឯណោះ វាល អាវាលដង្កៀបក្ដាមអីណោះឲ្យ ។

ឈុនលី ៖ មីងលើកមួយណាមុន?

ម៉ុត ៖ លើកត្រពាំងថ្មរួចបានយើងដើរចល័ត បើចល័តគ្រប់កន្លែងចឹង ។

ឈុនលី ៖ ទៅមកៗ?

ម៉ុត ៖ ចាំ! ទៅមកៗ ។

ឈុនលី ៖ ចុះនៅដង្កៀបក្ដាមហ្នឹងអ្នកណាអ្នកមើលការខុសត្រូវដែរ?

ម៉ុត ៖ គ្រូរស់ ហ្នឹងហើយគាត់អ្នកមើលកង ។

ឈុនលី ៖ មេធំទៀតណាស គាវ៉ាល់ ដែរអត់មេធំ?

ម៉ុត ៖ ទេ គ្រូរស់គាត់អ្នកដើរមើលជុំគ្នាជាមួយប្រធានកងប្រធានក្រុម ម៉ាកងធំអីចេះទៅគេយកទៅដាក់បួនដប់ថ្ងៃចេះទៅគេយកទៅដាក់ត្រង់ណោះ បួនដប់ថ្ងៃទៅគេយកទៅដាក់ត្រង់ណោះ ចល័តរហូតមិនមែនលើកតែម៉ាកន្លែងឯណា តែខ្វះកំលាំងគេយកយើងទៅដាក់ខ្វះយកទៅដាក់ គ្រប់កន្លែងចល័តគ្រប់កន្លែង ។

ឈុនលី ៖ ចេញពីគរបីដើមរួចទៅណាទៀត?

ម៉ុត ៖ ចេញពីគរបីដើមទៅនៅព្រៃមាន់ជាប់តែគ្នាទៅមកៗនៅនោះឲ្យតែខ្វះកំលាំង ។

ឈុនលី ៖ មីងអត់ដែលចូលភូមិទេ?

ម៉ុត ៖ ទេ មិនដែលចូលភូមិទេទាល់តែយួនចូលមកបានៗមកនៅក្នុងភូមិ ។

ឈុនលី ៖ ចុះពេលចូលមកភូមិហ្នឹងខ្មែរក្រហមចូលមកហើយនៅ?

ម៉ុត ៖ ទេ ខ្មែរក្រហមចេញទៅបានៗចូលមក ដែរយួនចូល ។

ឈុនលី ៖ យួនចូលមកហ្នឹងមីងនៅឯណា?

ម៉ុត ៖ យួនចូលមកនៅដើមគរបីដើម ។ ដើមគរបីដើម ពួកវារត់ចេះទៅក៏ខ្ញុំមកផ្ទះពួកអាប្រធានកងពួកនិរតីនោះក៏ដឹកជញ្ជូនផង វ៉ាន់ស៊ីៗអង្ករស្បៀងអីទៅកូនខ្វែងចេះទៅ ។

ឈុនលី ៖ ចុះមានប្រជាជនយើងរត់ទៅតាមខ្មែរក្រហមដែរអត់?

ម៉ុត ៖ ទេ អត់មានអ្នកណារត់ទៅទេ ទៅតែពួកនិរតីទេ ទៅពួកអាស្រួចអីគេទៅបានទៅខាងពួកនិរតី ពួកខ្ញុំនេះអត់មានអ្នកណាទៅទេ មានអីប្រាសមកផ្ទះវិញអស់ហើយអត់មានអ្នកណាទៅទេ ទៅតែពួកនិរតីនេះឯង ។ ពួកវាចេញតាមនេះពួកខ្ញុំទៅតាមនេះ ម៉ូតូ ម៉ាស៊ីនដេរស្ដី ស្រូវអង្ករនឹងដើមគរ អ្នកគ្រូអើយជម្រុកប៉ុនៗភ្នំច្រូតកាត់ កំពុងតែច្រូតណាស មិនដែលមានអីបញ្ឆោន់ អត់មានអីទេតែវ៉ៃ ស្រូវទាំងពំនូកមិនដឹងវាដឹកយកទៅណាទេវាមិនឲ្យយើងហូបណាស មិនដឹងវាយកទៅណា វាសុខចិត្តឲ្យយើងហូបម៉ាងៃតែម៉ាចានវាល់ម៉ាចានពីរថ្ងៃពីរចាន ។ ធ្វើបានកំភ្លុះកំភ្លាយ តែមិនដឹងយកទៅណាឆ្ងល់តែប៉ុណ្ណេះឯង ។

ឈុនលី ៖ មីងសុំសួរបកបន្តិចសិន អាពេលដែលគេចាប់មីងច្រឡំហ្នឹង ពេលអត់ចាប់មីងចឹងមានចាប់អ្នកផ្សេងទៀតដែរ?

ម៉ុត ៖ ចាប់ ។

ឈុនលី ៖ ចាប់ប៉ុន្មាននាក់?

ម៉ុត ៖ ពីរនាក់ ។

ឈុនលី ៖ ស្រីឬប្រុស?

ម៉ុត ៖ ស្រី ។

ឈុនលី ៖ ម៉េចបានចាប់ចឹង?

ម៉ុត ៖ គេថាវាយួន ។

ឈុនលី ៖ ពីរនាក់ហ្នឹងយួនមែនហ្អី?

ម៉ុត ៖ យួនមែន ។

ឈុនលី ៖ មកពីណា?

ម៉ុត ៖ មិនដឹងជាមកពីណា ឈ្មោះមួយសារី មួយទៀតមិនដឹងឈ្មោះអីទេ សរស្អុះ ចុះវាយួននោះ ។

ឈុនលី ៖ សាន់ហ្អី?

ម៉ុត ៖ ទេ សាន់នោះបងវាទេ ប្អូនដែលគេចាប់ ។

ឈុនលី ៖ ចុះយាំទេបង?

ម៉ុត ៖ បងវាគេយកទៅមុនបាត់ហើយ ។

ឈុនលី ៖ ចុះគេយកទៅពីរនាក់ក្រោយទៀតនោះ?

ម៉ុត ៖ ក្រោយទៀតមែតម្នាក់ទេ ។

ឈុនលី ៖ បងយកទៅដែរ?

ម៉ុត ៖ មីបងនោះគេយកទៅវៃមុនយូរណាស់ហើយ នៅតែមីប្អូនឈ្មោះស្ទីណាទេក្មេងឈ្មោះអស់ហើយ បើនៅជាមួយគ្នាស្គាល់ នឹករកមិនឃើញទេ ។

ឈុនលី ៖ ហើយពេលចូលភូមិពេលវៀតណាមចូលមីងចូលភូមិណា?

ម៉ុត ៖ ភូមិនេះហើយ ។

ឈុនលី ៖ មកជាមួយអ្នកណាគេខ្លះ?

ម៉ុត ៖ កាលវៀតណាមចូលមកខ្ញុំនៅដក់ពរនោះ ម៉ែខ្ញុំនៅឯនោះឯងដែលយូនចូលមក ។

ឈុនលី ៖ នៅដក់ពរ?

ម៉ុត ៖ ចា៎!

ឈុនលី ៖ ផ្ទះបងហ្នឹងហ្អី?

ម៉ុត ៖ ហ្នឹងហើយ ។

ឈុនលី ៖ នៅជុំគ្នានៅហ្នឹង?

ម៉ុត ៖ ជុំគ្នា ។

ឈុនលី ៖ ចុះក្រោយមកមកនៅភូមិនេះពេលណា?

ម៉ុត ៖ ដល់មើលទៅគេដេញថាយកស្រែយកចំការដីធ្លីទៅ យើងមកស្រុកយើងវិញ ។

ឈុនលី ៖ យកដីធ្លីយ៉ាងម៉េច?

ម៉ុត ៖ ដីគេចែកណាស ។

ឈុនលី ៖ គេចែកគ្នាហ្អី?

ម៉ុត ៖ ហ្នឹងហើយគេចែកគេដេញបើនៅឯណោះអីណាបើដីគេចឹងយើងមកនៅដីយើងវិញ ។

ឈុនលី ៖ ហ្អស!មកនៅផ្ទះយើងវិញ?

ម៉ុត ៖ ចា៎!

ឈុនលី ៖ ផ្ទះមីងមកដល់ឃើញខូចខាតទេ?

ម៉ុត ៖ ទេ មិនមាននៅទេ វើខ្ទេចខ្ទីរអស់ឆេះអស់ ។

ឈុនលី ៖ ឆេះអស់អីចឹងមិនត្រូវធ្វើឡើងវិញ?

ម៉ុត ៖ ធ្វើអីធ្វើកូនខ្ទមនៅ ខ្ញុំទើបតែបានលើកផ្ទះនៅបានប្រហែល៥ខែ នៅតែកូនខ្ទមតូចញ៉ឹបហ្នឹង ។

ឈុនលី ៖ តាំងពីនោះមក?

ម៉ុត ៖ ចាំ! តាំងពីយួនចូលមកទើបតែធ្វើបានកូនខ្ទម ខ្ញុំទើបតែលើកខែកក្តិក ។

ឈុនលី ៖ ផ្ទះមីងនៅឯណា?

ម៉ុត ៖ នោះផ្ទះខ្ញុំនៅខាងក្រោយ ។

ឈុនលី ៖ ហើយមកដល់មីងមានគ្រួសារពេលណា?

ម៉ុត ៖ មានគ្រួសារយូរដែរហើយគ្រួសារខ្ញុំបានសាមប៉ុន្មាន បានប្តីសាមប្រាំ ។

ឈុនលី ៖ ហើយពេលមកវិញរកស៊ីអីទៅ?

ម៉ុត ៖ ធ្វើស្រែចឹងទៅ ។

ឈុនលី ៖ ម៉េចក៏ក្រយកគ្រួសារម្ល៉េះមីង?

ម៉ុត ៖ បើទើបតែបាននោះ មានកូនធំហើយ ។

ឈុនលី ៖ ការហើយនៅឯណា?

ម៉ុត ៖ ការហើយនៅនេះហើយ ។

ឈុនលី ៖ ធ្វើស្រែទៅ?

ម៉ុត ៖ ចាំ! ទេធ្វើទាហាន ។

ឈុនលី ៖ ធ្វើទាហាន ហើយមីងធ្វើស្រែ?

ម៉ុត ៖ ខ្ញុំមិនបានធ្វើស្រែទេ ខ្ញុំឈប់ហើយដល់បានប្តីខ្ញុំឈប់ហើយ ។ ឈប់ធ្វើស្រែទៅនៅទាហាន ។

ឈុនលី ៖ ហួស! តែមកនៅដំបូងធ្វើស្រែធ្វើអីទៅហើយបាន១ប្តី?

ម៉ុត ៖ ចាំ!

ឈុនលី ៖ ប្តីធ្វើទាហាន?

ម៉ុត ៖ ប្តីធ្វើទាហាន ។

ឈុនលី ៖ ទាហានខ្មែរក្រហមឬទាហានយើង?

ម៉ុត ៖ ទេ ទាហានយើងនេះឯង ។

ឈុនលី ៖ គាត់ធ្វើទាហានពេលណា?

ម៉ុត ៖ ពេលវៀតណាមចូលមកធ្វើម្ភៃឆ្នាំផ្ទាយហើយ ។

ឈុនលី ៖ ឥឡូវគាត់ធ្វើទៀត?

ម៉ុត ៖ ទេ គាត់ឈប់ធ្វើហើយ ។

ឈុនលី ៖ មានពិការអីដែរអត់?

មុំត ៖ នេះកំបុតដៃត្រឹមនេះ ។

ឈុនលី ៖ ម៉េចចឹង?

មុំត ៖ ត្រូវគ្រាប់ត្រូវដៃ ដៃគាត់កំបុតអស់ពីរ ។

ឈុនលី ៖ ហើយមីងបានកូនប៉ុន្មាន?

មុំត ៖ កូនប្រាំ ។

ឈុនលី ៖ បានរៀនសូត្រទេកូន?

មុំត ៖ កូនរៀនអាមួយថ្នាក់ទី៥ ទី៨ ទី៥តែវាឈប់អស់ហើយអ្នកគ្រូអើយ វាមិនរៀនទេ ។ អាមួយនោះទៅបាងកក ។

ឈុនលី ៖ នេះកូនពៅហ្អី?

មុំត ៖ ទេ អាពៅតូចជាងនេះ នេះថ្នាក់ទី៥ ។

ឈុនលី ៖ មីងដែលឮរឿងគេកាត់ទោសខ្មែរក្រហមទេ?

មុំត ៖ ទេ មិនដែលបានដឹងផង ។

ឈុនលី ៖ ដែលស្ដាប់វ៉ាត់យូដែរអត់?

មុំត ៖ ហើយហើយ តែគេកាត់ដែរមិនដឹងគេកាត់ថ្ងៃណា ។

ឈុនលី ៖ កាត់ នួន ជា អៀង សារី ខៀវ សំផន អៀង ធិរិទ្ធ ហើយហ្នឹង ឌុច ។ ឌុចមេគុកទួលស្លែង ។

មុំត ៖ ឃើញគេថតដាក់ទូរទស្សន៍ដែរ ។

ឈុនលី ៖ មីងសប្បាយចិត្តពេលមានការកាត់ទោសចឹង?

មុំត ៖ សប្បាយចិត្តហើយបើវាធ្វើបាបយើងកាលនោះវេទនាដេកហាលភ្លៀងហាលផ្គរ ។

ឈុនលី ៖ ចុះមីងចង់ឲ្យគេកាត់ទោសយ៉ាងម៉េច?

មុំត ៖ មិនដឹងគេកាត់ទោសយ៉ាងម៉េចហ្អាស ចាំមើលគេ ។

ឈុនលី ៖ ចង់ឲ្យធ្វើម៉េច?

មុំត ៖ ចង់វៃសម្លាប់បែបគេមិនសម្លាប់ទេដឹង?

ឈុនលី ៖ គេអត់សម្លាប់ទេសម័យនេះគេកាត់ទោសដាក់គុកប៉ុន្មានឆ្នាំៗអីចឹងទៅណាស ។

មុំត ៖ មិនបាច់សំលាប់ទេទុកឲ្យគាត់កែខ្លួនទៅដឹង?

ឈុនលី ៖ គាត់ចាស់ៗហើយ អាយុប៉ែតជាងហើយមីងគិតថាគួរតែកាត់ទោសគាត់ដែរអត់?

មុំត ៖ ទេ កាត់ទោសយ៉ាងណាឲ្យគាត់ទៅនៅវត្តទៅដឹង ។

ឈុនលី ៖ អីចឹងអត់ចង់កាត់ទោសចង់ឲ្យគាត់ទៅនៅវត្ត?

ម៉ុត ៖ បានបុណ្យបានទានព្រោះគាត់បាបច្រើន សំលាប់មនុស្សអស់ច្រើន ។

ឈុនលី ៖ ចុះបើតុលាការគេអត់ឲ្យទៅ ។

ម៉ុត ៖ បើតុលាការគេមិនឲ្យទៅយើងកាត់តាមតុលាការទៅ ឲ្យតុលាការសំលាប់គាត់ទៅ ។

ឈុនលី ៖ អត់សម្លាប់ទេ មានតែដាក់ទោស ។ មានអីទៀតទេមីង?

ម៉ុត ៖ អត់មានអីទៀតទេ ។

ឈុនលី ៖ អគុណហើយមីងណាស ។ អ្នកណាអ្នកទទួលខុសត្រូវនៅកូនខ្វែងណាស?

ម៉ុត ៖ អ្នកនិរតី ។

ឈុនលី ៖ ដដែលហ្អី?

ម៉ុត ៖ ចា៎!

ឈុនលី ៖ អ្នកនៅត្រពាំងថ្មដូចអ្នកនៅកូនខ្វែងហ្អី?

ម៉ុត ៖ ដែរ និរតី ពួកនិរតី ។ គ្រូរស់នោះខ្ញុំនៅជាមួយគាត់រហូត ។

ឈុនលី ៖ មីងថាគាត់នៅភូមិអី?

ម៉ុត ៖ នៅប៉ោយសំរោង ។

ឈុនលី ៖ ឆ្ងាយទេ?

ម៉ុត ៖ នេះរំលងភូមិនេះទៅដល់ហើយជាប់ហ្នឹងដែរ ។

ឈុនលី ៖ គាត់អាយុប៉ុន្មានហើយ?

ម៉ុត ៖ អាយុមិនដឹងប៉ុន្មានហើយទេ ហាហុកហើយដឹង ។

ឈុនលី ៖ ស្រីទេ?

ម៉ុត ៖ ស្រី ។

ឈុនលី ៖ មីងស្គាល់យាយបែមទេ?

ម៉ុត ៖ យាយបែម ខ្ញុំស្គាល់ដែរតើ ។

ឈុនលី ៖ យ៉ាងម៉េចខ្វះយាយបែមគាត់មកពេលណា?

ម៉ុត ៖ យាយបែម យូរៗគាត់មកម្តង ។

ឈុនលី ៖ យាយបែម គាត់នៅឯណា?

ម៉ុត ៖ មិនដឹងនៅឯណាឮថានៅអន្លង់វែង ។

ឈុនលី ៖ កាលពីមុន មុននឹងគាត់មកគាត់មកឆ្នាំណា?

ម៉ុត ៖ មិនដឹងផងតែយូរៗគាត់មកម្តង?

ឈុនលី ៖ មកណា?

ម៉ុត ៖ មកកន្លែងពួកខ្ញុំ ។

ឈុនលី ៖ ទៅមើលដល់ណា?

ម៉ុត ៖ ទៅមើលនៅព្រៃមាន់ គរបីដើម ។

ឈុនលី ៖ ចុះគាត់ទៅត្រពាំងថ្មដែរអត់?

ម៉ុត ៖ ត្រពាំងថ្មក៏គាត់ទៅដែរ ។

ឈុនលី ៖ ចុះកាលមីងនៅត្រពាំងថ្មឃើញគាត់ដែរអត់?

ម៉ុត ៖ ទៅ ។

ឈុនលី ៖ ហើយទៅគាត់ធ្វើម៉េច?

ម៉ុត ៖ មានម៉េចទៅគាត់ដើរតែលើខ្នងទំនប់ ដើរមើលយើង ។

ឈុនលី ៖ យាយថែមគាត់រូបរាងយ៉ាងម៉េច?

ម៉ុត ៖ យាយថែម គាត់ក្តោបក្តាប់យើងដូចជាម៉ាស្រុក ម៉ាឃុំ ដូចម៉ាស្រុកព្រះនេត្រព្រះ ។

ឈុនលី ៖ ក្តាប់ម៉ាស្រុកម៉ង?

ម៉ុត ៖ ចាស ម៉ាស្រុក ម៉ាខេត្តផងដឹងបើខ្ញុំមិនសូវដឹងផងគេអ្នកធំៗ បើមីងដែលគាត់ចល័តតំបន់ តែគាត់គាត់ឈឺគាត់និយាយមិនកើត បើគាត់និយាយកើតឲ្យគាត់...

ឈុនលី ៖ ចុះគ្រូរស់ហ្នឹងគាត់ដឹងទេ?

ម៉ុត ៖ គ្រូរស់បែបគាត់ដឹងទេដឹងបើគាត់នៅជាមួយ គាត់អ្នកធ្វើការគាត់ប្រធានកងប្រធានវរៈ ។

ឈុនលី ៖ រូបរាងយ៉ាងម៉េចយាយថែម គាត់អ្នកនិរតីទេ?

ម៉ុត ៖ ទេ ដូចមិនមែននិរតីទេពាយ័ព្យយើងហ្នឹង ។ រូបរាងខ្មៅ ស្រអែម គាត់ទាបសមរូបសម រាង ។

ឈុនលី ៖ គាត់ស្អាតទេ?

ម៉ុត ៖ មានអីស្អាតសមតែគាត់មាឌតូច ។

ឈុនលី ៖ គាត់កាចទេ?

ម៉ុត ៖ ទេ មិនកាចណាស់ណាទេធម្មតា ។

ឈុនលី ៖ ចុះអ្នកស្រុកអ្នកភូមិស្អប់គាត់ទេ?

ម៉ុត ៖ ទេ មិនសូវមានអ្នកណាស្អប់គាត់ទេ បើមិនដែលឲ្យអ្នកណាអត់ទេ តែឃ្លានឲ្យហូបហើយឲ្យតែចល័តតំបន់ហូបឆ្អែតៗអត់តែចល័តភូមិខ្ញុំទេ ។

ឈុនលី ៖ ចុះមីងគេហៅចល័តអីគេ?

ម៉ុត ៖ ចល័តយើងគ្រប់កន្លែង ។

ឈុនលី ៖ ចុះចល័តតំបន់ហ្នឹងចល័តយ៉ាងម៉េច?

ម៉ុត ៖ ចល័តម៉ាកន្លែងៗមិនដូចខ្ញុំចល័តគ្រប់ភូមិគ្រប់ស្រុកបើគេខ្វះកំលាំងគេយកយើងទៅដាក់ដល់តែកន្លែងណាខ្វះគេដកយើងទៅដាក់ទៀត មិនសូវបាននៅទេចល័តរហូត ។ បើចង់ដឹងទៅសួរគ្រូរស់ ព្រោះខ្ញុំប្រជាជនមិនសូវដឹងទេ គាត់ជំនាន់ពួកយាយថែម ពួកតាម៉ោងអីគាត់ហ្នឹងឯងពេលទៅប្រជុំ ។ ប្រជុំម្តងៗខ្ញុំនៅដើមគរ គេឲ្យខ្ញុំធ្វើប្រធានកងដែរប្រធានកងតូច តែខ្ញុំបានទៅប្រជុំដែរ ប្រជុំតែខ្ញុំមិនចេះអក្សរ ខ្ញុំថាខ្ញុំមិនបានចេះអក្សរទេខ្ញុំមិនធ្វើទេប្រធានកងតូចអីខ្ញុំមិនធ្វើទេ ។ គេថាគេយកអ្នកមិនចេះ អ្នកចេះគេមិនបានយកទេទៅប្រជុំអាជិតរដ្ឋប្រហារហើយនេះ អាដែងជិតយួនចូលនេះអ្នកគ្រូអឺយមិនបានច្រូតស្រូវច្រូតអីទេព្រឹកឡើងប្រជុំល្ងាចឡើងប្រជុំព្រឹកឡើងប្រជុំៗ រាល់ថ្ងៃ ។

ឈុនលី ៖ អត់ធ្វើការទេ?

ម៉ុត ៖ ទេ ប្រធានកងៗណាស កូនកងធ្វើការធម្មតា អាពួកប្រធានហ្នឹងពីរបីថ្ងៃប្រជុំ ម្ង៉ៃប្រជុំៗអាណាប្រមូលមាស ប្រមូលប្រាក់ ។

ឈុនលី ៖ ប្រជុំរឿងប្រមូលអីចឹង?

ម៉ុត ៖ ចាស អ្នកថ្មីវាដាំក្នុងកំសៀវអីចេះណាស ដាំម៉ាកំសៀវដាក់ទឹកដឹកគេដាក់ថ្នាំពីលើ ។ ពួកនិរតីវាឲ្យប្រជុំអ្នកណាពាក់មាសពាក់អី ពួកអ្នកថ្មីវាសំបូរមាសពាក់ក៏ប្រមូលគ្នាហើយគេឲ្យខ្ញុំថាយកទៅដាក់ខ្សែចង្កៀងទៅ ប៉ុនៗណេះអ្នកគ្រូអឺយខ្ញុំអត់ហានយករបស់គេទេ បើយកតែម៉ាខ្សែទៅ អាយួនចូលមកនេះវាបានហើយ...តែខ្ញុំមិនហានយកទេ ប៉ុនៗណេះគេប្រមូលបានទៅក៏ប្រកចង់ពួកអ្នកថ្មីចាក់ចេញពីកំសៀវមកក៏ប៉ុណ្ណេះឯងឲ្យក្រហមដូសុទ្ធតែខ្សែម៉ាកំសៀវប៉ុណ្ណេះឯង ថាក្រហមឆ្អៅគេថាឲ្យយកទៅធ្វើចង្កៀងបានមួយទៅ ហើយខ្ញុំថាបងអឺយមិនបានយកទេ ចុះយើងកាលនោះហៅតែបងនោះ ថាវាឆ្កួតបើគេឲ្យហើយមិនព្រមយក ។

ឈុនលី ៖ ម៉េចបានអត់យកចឹង?

ម៉ុត ៈ ថាវាឆ្អួតខ្លួនឯងបើគេឲ្យហើយក៏មិនយកអីហ្អាស មិនយកទេដល់តែចេះទៅបាននឹកឃើញស្តាយណាស់ដឹងអីចឹងយកមកពីរបីខ្សែ ចុះបើប្រមូលមកទាំងស្តិលអីចេះឯង ។ មាសពីដើមមិញក្រហមដូចរមៀតស្អុយ ។

ឈុនលី ៈ មឹងកាលលើកមុនពេលវៀតណាមចូលមកនៅនេះមិនមែនខេត្តបន្ទាយមានជ័យឯណាហ្អី?

ម៉ុត ៈ ខេត្តបន្ទាយមានជ័យ ។

ឈុនលី ៈ មិនមែនទេហ្អីបាត់ដំបងទេហ្អី?

ម៉ុត ៈ ទេ បន្ទាយមានជ័យ ។

ឈុនលី ៈ ពីដើមមមបន្ទាយមានជ័យ?

ម៉ុត ៈ បន្ទាយមានជ័យ ។

ឈុនលី ៈ នៅនេះគេហៅតំបន់អីគេពីដើមមក?

ម៉ុត ៈ តំបន់ប្រាំ ។

ឈុនលី ៈ អ្នកណាគ្រប់គ្រងតំបន់ប្រាំ?

ម៉ុត ៈ មិនដឹងជាអ្នកណាគ្រប់គ្រងតំបន់ហ្អាសខ្ញុំមិនដឹងបើយូរចេះទៅ ។ តំបន់ប្រាំតំបន់ខ្លាំងលេខមួយដាច់លេខគេហើយតំបន់ប្រាំ ។

ឈុនលី ៈ ខ្លាំងរឿងអី?

ម៉ុត ៈ ខ្លាំងពីរឿងស៊ីរឿងចុកពីរឿងវ៉ៃពីរឿងអីណាស វ៉ៃខ្លាំងជាងគេទាំងអស់ ។ វ៉ៃនៅស្រុកក្នុងភូមិយើងនេះឲ្យតែខុសអីបន្តិចវ៉ៃហើយ ។

ឈុនលី ៈ ម៉េចក៏តឹងម្ល៉េះ?

ម៉ុត ៈ ហ៊ឹស!ថាតឹងលេខមួយតំបន់ប្រាំដាច់គេតំបន់ប្រាំរឿងស៊ីចុក ។

ឈុនលី ៈ អ្នកគ្រប់គ្រងមកពីណាបានតឹងម៉េះ?

ម៉ុត ៈ មកពីខាងណាមកពីនិរតី តឹងបំផុត តឹងបំផុតពេលពួកនិរតីមកដល់ភ្លាម តឹងមហាសែនអស្ចារ្យហើយ ។

ឈុនលី ៈ ឆ្នាំណាកាលនោះ?

ម៉ុត ៈ មិនដឹងឆ្នាំណាពួកនិរតីមក មិនដឹងឆ្នាំប៉ុន្មាន ហើយវាគំរោងការវាចង់ដាក់នែ!ជិតចប់នេះគំរោងការវាចង់ដាក់នំបញ្ចុក គេធ្វើនំបញ្ចុកឲ្យយើងស៊ីតែគេដាក់ថ្នាំឲ្យយើងងាប់អស់

ហើយគេរើសនារី កាលនោះគេរើសនារីតែ១៥នាក់ទេ រើសឲ្យស្អាតយកទៅបង្កាត់ចិន ។ ព្រោះកាលនោះយើងងាប់អស់ហើយនៅសល់តែម៉ានេះទៀតយើងងាប់អស់ហើយ ។

ឈុនលី : ម៉េចបានមីងដឹង?

មុ៉ត : ចុះបើខ្ញុំទៅប្រជុំក៏ខ្ញុំដឹង ។

ឈុនលី : ប្រជុំថាម៉េច?

មុ៉ត : ប្រជុំថាយើង តែគេបង្កើងដានដែរមិនសូវឲ្យយើងដឹង ថានៅតែផែនការ ដល់នេះទៅ សំបុត្រគេបោះមកស្រាប់តែគេរើសសំបុត្របាន ។

ឈុនលី : អ្នកណារើសបាន?

មុ៉ត : មិនដឹងអ្នកណារើសបានពេលកប៉ាល់ហោះបើកមកសំបុត្រវាធ្លាក់មក ។

ឈុនលី : សំបុត្រធ្លាក់ពីកប៉ាល់ហោះមក?

មុ៉ត : ហ្នឹងហើយធ្លាក់ពីលើកប៉ាល់ហោះ គេរើសបានមកគេថានឹងវ៉ៃចោលឲ្យអស់ម៉ាតំបន់ប្រាំហ្នឹងណាស វ៉ៃចោលឲ្យអស់ធ្វើនំបញ្ចុកឲ្យស៊ី តែធ្វើវាមិនទាន់គ្រាន់តែយួនចូលមកក៏បានរស់មកប៉ុណ្ណេះកុំអីហ្នឹងមិនដឹងទៅណាអស់ហើយ កើតជាដេះជាធ្យូងអស់ហើយ ។

« ចប់ »